ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ផែនការសកម្មភាពជាតិ
# សុខភាពមាត់ធ្មេញ២០២៣-២០៣០

នាយកដ្ឋានការពារសុខភាព

២០២៣

# អារម្ភកថា

ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញ២០២៣-២០៣០ រៀបចំដោយអនុលោមតាមគោលការណ៍នៃផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការការពារនិងប្រយុទ្ធនឹងជំងឺមិនឆ្លង ផែនការសកម្មភាពសុខភាពមាត់ធ្មេញសកល២០២៣-២០៣០ របស់អង្គការសុខភាពពិភពលោក ដោយផ្អែកលើបទពិសោធន៍និងមេរៀនដែលទទួលបានពីការអនុវត្តការងារកន្លងមក។

ជំងឺមាត់ធ្មេញជាជំងឺដែលអាចការពារបាន ប៉ុន្តែស្ថានភាពសុខភាពមាត់ធ្មេញរបស់ប្រជាជនកម្ពុជាបច្ចុប្បន្ន មិនទាន់មានសភាពល្អប្រសើរនៅឡើយ ដោយសារអត្រាប្រេវ៉ាឡង់ខ្ពស់ ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចគ្រួសារ និងសង្គម ព្រមទាំងគុណភាពនៃជីវិតរស់នៅ។ ការថែទាំដោយការដុសសម្អាតជាប្រចាំ ការប្រកាន់ខ្ជាប់នូវឥរិយាបទល្អចំពោះសុខភាពមាត់ធ្មេញ ព្រមទាំងចៀសវាងនូវកត្តាហានិភ័យមួយចំនួនដូចជា ការបរិភោគអាហារនិងភេសជ្ជៈដែលមានជាតិស្ករ ការប្រើប្រាស់ថ្នាំជក់ ការប្រើប្រាស់គ្រឿងស្រវឹង និងទម្លាប់ទំពាម្លូស្លា នឹងអាចជួយកាត់បន្ថយបន្ទុកជំងឺមាត់ធ្មេញបាន។ តាមរយៈផែនការនេះ សកម្មភាពសំខាន់ៗបានលើកឡើង ដោយដាក់បញ្ចូលផ្នែកសុខភាពមាត់ធ្មេញទៅក្នុងកម្មវិធីថែទាំសុខភាពបឋម ដើម្បីអនុវត្តន៍នូវការការពារជំងឺពុកធ្មេញរបស់កុមារ តាមសហគមន៍និងគ្រឹះស្ថានសិក្សា កាត់បន្ថយបញ្ហាមាត់ធ្មេញសម្រាប់មនុស្សចាស់ និងការស្រាវជ្រាវរកជំងឺមហារីកប្រអប់មាត់ដំណាក់កាលដំបូងរួមទាំងដំបៅមាត់ដែលអាចបង្កជាជំងឺមហារីក និងចាត់បញ្ជូនទៅព្យាបាលឱ្យបានទាន់ពេល។

ផែនការសកម្មភាពនេះ បង្ហាញពីវិធានការឆ្លើយតបស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល និងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលយកចិត្តទុកដាក់ចំពោះការរស់នៅរបស់ប្រជាជនកម្ពុជាប្រកបដោយសុខុមាលភាពពេញមួយជីវិត។ ការលើកកម្ពស់សុខភាពនិងការពារការកកើតឡើងនៃជំងឺ តាមរយៈការថែទាំសុខភាពបឋមដោយផ្តោតលើប្រជាជនជាគោល ការគ្របដណ្តប់សុខភាពជាសកល និងការគ្រប់គ្រងជំងឺមិនឆ្លងនានា ដែលរួមបញ្ចូលផ្នែកសុខភាពមាត់ធ្មេញផងដែរ។

ក្រសួងសុខាភិបាល សូមជំរុញគ្រប់ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ឱ្យចាត់ទុកបញ្ហាមាត់ធ្មេញជាអាទិភាព និងធ្វើការរួមគ្នា ដើម្បីអនុវត្តសកម្មភាពការងារនានាក្នុងការកាត់បន្ថយបន្ទុកនៃជំងឺមាត់ធ្មេញប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ចន្ទ ៩ កើត ខែ បឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ម៉ម ប៊ុនហេង**

# សេចក្តីថ្លែងអំណរគុណ

ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញ២០២៣-២០៣០ ត្រូវបានរៀបចំបង្កើតឡើងក្រោមការដឹកនាំរបស់ការិយាល័យសុខភាពមាត់ធ្មេញ នាយកដ្ឋានការពារសុខភាពនៃក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក និងមូលនិធិ Borrow Foundation។

ក្រសួងសុខាភិបាលសូមសម្តែងនូវការកោតសរសើរដោយស្មោះ ចំពោះស្ថាប័ននិងអង្គភាពពាក់ព័ន្ធនានា ដែលរួមមាន៖ នាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យមជ្ឈមណ្ឌលជាតិ អង្គការដៃគូអភិវឌ្ឍន៍សុខាភិបាល និងក្រុមការងាររៀបចំបង្កើតសៀវភៅផែនការសកម្មភាពដែលបានខិតខំប្រឹងប្រែងចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើក ដើម្បីពិនិត្យកែតម្រូវនូវខ្លឹមសារនិងបញ្ចប់ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់អង្គការសុខភាពពិភពលោកនិងមូលនិធិ Borrow Foundation សម្រាប់ការគាំទ្រលើផ្នែកបច្ចេកទេសនិងថវិកា ក្នុងដំណើរការរៀបចំនិងបង្កើតផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញ២០២៣-២០៣០។ ផែនការសកម្មភាពនេះ នឹងផ្តល់ជាគោលមាគ៌ាណែនាំសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពលើការងារលើកកម្ពស់និងការពារថែទាំសុខភាពមាត់ធ្មេញជូនដល់ប្រជាជនកម្ពុជា។

# មាតិកា

ទំព័រ

**អារម្ភកថា** i
សេចក្តីថ្លែងអំណរគុណ ii
មាតិកា iii
អក្សរកាត់ iv
**១- សារធាន** ............ 1
១.១- គោលនយោបាយ ............ 1
១.២- ស្ថានភាព ............ 4
១.៣- បញ្ហាអាទិភាព ............ 8
**២- គោលបំណង** ............ 12
**៣- យុទ្ធសាស្ត្រ** ............ 13
៣.១- គោលការណ៍ណែនាំ ............ 14
៣.២- ចំណុចដៅដាក់លាក់ត្រឹមឆ្នាំ២០៣០ ............ 16
**៤- ផែនការសកម្មភាព** ............ 17
៤.១- វិសាលភាពនៃផែនការ ............ 17
៤.២- តារាងសកម្មភាពការងារ ............ 17
**៥- ការចំណាយ** ............ 24
**៦- ការពិនិត្យតាមដាននិងវាយតម្លៃ** ............ 31
**៧- សេចក្តីសន្និដ្ឋាន** ............ 37
**៨- ឯកសារយោង** ............ 38

# អក្សរកាត់

| | |
|---|---|
| **ART** | Atraumatic Restorative Technique ( ការបិទប៉ះធ្មេញដោយបច្ចេកទេសART ) |
| **BPOC** | Basic Package of Oral Care ( ការថែទាំមាត់ធ្មេញជាមូលដ្ឋាន ) |
| **CIPO** | Collaborating Centre for Innovation in Population Oral Health<br>( មជ្ឈមណ្ឌលសហប្រតិបត្តិការសម្រាប់នវានុវត្តន៍សុខភាពមាត់ធ្មេញប្រជាជន ) |
| **CMS** | Central Medical Stock ( ឃ្លាំងឱសថកណ្ដាល ) |
| **CPA** | Complimentary package of activities ( សំណុំសកម្មភាពបង្គ្រប់ ) |
| **DCC** | Dental Council of Cambodia ( គណៈទន្តពេទ្យកម្ពុជា ) |
| **DDF** | Department of Drugs and Food ( នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង ) |
| **DHRD** | Department of Human Resource Development ( នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ) |
| **DHS** | Department of Hospital and Services ( នាយកដ្ឋានមន្ទីរពេទ្យ ) |
| **DMFT** | Decayed, Missing and Filled Teeth<br>( ជាសន្ទស្សន៍សម្រាប់គណនារកចំនួនធ្មេញពុក ធ្មេញបាត់បង់ និងធ្មេញដែលបានបិទប៉ះរួច ) |
| **DoEYS** | Department of Education Youth and Sport (at province) ( មន្ទីរអប់រំតាមបណ្ដាខេត្ត ) |
| **DPHI** | Department of Planning and Health Information ( នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាល ) |
| **ECC** | Early Childhood Caries ( ជំងឺពុកធ្មេញលើកុមារតូច ) |
| **FFS** | Fit For School ( គម្រោងអនាម័យគំរូតាមសាលារៀន ) |
| **FV** | Fluoride Varnish ( ភ្លុយអរ៉ាយវ៉ានីស ជាថ្នាំលាបការពាររោគពុកធ្មេញ ) |
| **GIZ** | Deutsche Gesellschaft fur Internationale Zusammenarbeit: German development Partner ( កិច្ចសហប្រតិបត្តការរបស់ប្រទេសអាល្លឺម៉ង់ ) |
| **HC** | Health Centre ( មណ្ឌលសុខភាព ) |
| **HIS** | Health Information System ( ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល ) |
| **MOH** | Ministry of Health ( ក្រសួងសុខាភិបាល ) |
| **MPA** | Minimum Package of Activities ( សំណុំសកម្មភាពអប្បរមា ) |
| **NAPOH** | National Action Plan for Oral Health ( ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញ ) |
| **NCD** | Non-Communicable Diseases ( ជំងឺមិនឆ្លង ) |
| **NCHP** | National Centre for Health Promotion ( មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព ) |
| **NGO** | Non-Governmental Organisation ( អង្គការមិនមែនរដ្ឋាភិបាល ) |

| | |
|---|---|
| **NIPH** | National Institute of Public Health (វិទ្យាស្ថានជាតិសុខភាពសាធារណៈ) |
| **NMCHC** | National Maternal and Child Health Centre (មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក) |
| **NOHS** | National Oral Health Survey (ការសិក្សាអង្កេតស្រាវជ្រាវផ្នែកសុខភាពមាត់ធ្មេញថ្នាក់ជាតិ) |
| **OC** | Oral Cancers (ជំងឺមហារីកប្រអប់មាត់) |
| **OD** | Operational District (ស្រុកប្រតិបត្តិ) |
| **OHB** | Oral Health Bureau (ការិយាល័យសុខភាពមាត់ធ្មេញ) |
| **OPMD** | Oral Potentially Malignant Disorder (ដំបៅក្នុងមាត់ដែលអាចប្រឈមជាជំងឺមហារីក) |
| **PHC** | Primary Health Care (ការថែទាំសុខភាពបឋម) |
| **PHD** | Provincial Health Department (មន្ទីរសុខាភិបាលរាជធានី/ខេត្ត) |
| **PMD** | Preventive Medicine Department (នាយកដ្ឋានការពារសុខភាព) |
| **PUFA** | Pulpal involvement, Ulceration, Fistula and Abscess (ជាសន្ទស្សន៍សម្រាប់គណនារកចំនួនធ្មេញពុក ដែលបានរាលចូលដល់បណ្តូលធ្មេញ មានបង្កជាដំបៅ មានបំពង់បង្ហូរខ្ទុះតូច និងមានអាប់សែ) |
| **RH** | Referral Hospital (មន្ទីរពេទ្យបង្អែក) |
| **RTC** | Regional Training Centre (សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ) |
| **SDF** | Silver Diamine Fluoride (ជាប្រភេទថ្នាំលាបដើម្បីទប់ស្កាត់ការរីករាលដាលជំងឺពុកធ្មេញ) |
| **SHD** | School Health Department, Ministry of Education Youth and Sport<br>(នាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា) |
| **Sub-TWGOH** | Sub Technical Working Group for Oral Health<br>(អនុគណៈកម្មការបច្ចេកទេសផ្នែកសុខភាពមាត់ធ្មេញ) |
| **UHC** | Universal Health Coverage (ការគ្របដណ្តប់សុខភាពជាសកល) |
| **UAC** | Universal Access to Care (ការទទួលបាននូវការថែទាំសុខភាពជាសកល) |
| **WHO** | World Health Organisation (អង្គការសុខភាពពិភពលោក) |

# ១- សារបាន

## ១.១- គោលនយោបាយ

យោងតាមនិយមន័យរបស់អង្គការសុខភាពពិភពលោកបានលើកឡើងថា សុខភាពមាត់ធ្មេញគឺជាស្ថានភាពនៃមាត់ ធ្មេញ និងរចនាសម្ព័ន្ធនៃមុខមាត់ ដែលអាចឱ្យបុគ្គលម្នាក់ៗបំពេញមុខងារសំខាន់ៗដូចជាការបរិភោគ ការដកដង្ហើម ការនិយាយ និង រួមបញ្ចូលទាំងខាងផ្នែកផ្លូវចិត្តដូចជា ទំនុកចិត្តលើខ្លួនឯង សុខុមាលភាព សមត្ថភាពក្នុងការធ្វើការងារនិងការប្រាស្រ័យទាក់ទងក្នុងសង្គម ដោយគ្មានការឈឺចាប់ ភាពរំខាន និងការខ្មាស់អៀន។ សុខភាពមាត់ធ្មេញល្អគឺមានសារៈសំខាន់ចំពោះសុខភាពទូទៅ សុខុមាលភាព និងគុណភាពនៃជីវិតរបស់មនុស្សម្នាក់ៗចាប់តាំងពីចាប់កំណើតរហូតដល់វ័យចាស់[១]។

នៅឆ្នាំ២០១៩ មានសេចក្តីប្រកាសគោលនយោបាយដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់ស្តីពីការគ្របដណ្តប់សុខភាពជាសកល ដែលមហាសន្និបាតអង្គការសហប្រជាជាតិបានអះអាងនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង រួមទាំងការពង្រឹងនិងពង្រីកកិច្ចខិតខំប្រឹងប្រែង ដើម្បីដោះស្រាយបញ្ហាសុខភាពមាត់ធ្មេញដែលជាផ្នែកមួយនៃការគ្របដណ្តប់សុខភាពសកល(UHC)។

បន្ទាប់ពីសេចក្តីប្រកាសនេះ យុទ្ធសាស្រ្តជាសកលសម្រាប់ការដោះស្រាយបញ្ហាមាត់ធ្មេញ ត្រូវបានចេញផ្សាយនិងផ្តល់ជាគោលការណ៍ណែនាំដូចតទៅ៖ (១)អនុវត្តវិធីសាស្រ្តសុខភាពសាធារណៈសម្រាប់សុខភាពមាត់ធ្មេញ (២)រួមបញ្ចូលសុខភាពមាត់ធ្មេញទៅក្នុងការថែទាំសុខភាពបឋម (៣)ជំរុញនវានុវត្តន៍លើភាពជាគំរូនៃកម្លាំងធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាពមាត់ធ្មេញរបស់ប្រជាជន (៤)ការថែទាំសុខភាពមាត់ធ្មេញដោយផ្តោតយកប្រជាជនជាគោល (៥)ការធ្វើអន្តរាគមន៍ថែទាំសុខភាពមាត់ធ្មេញពេញមួយជីវិត និង(៦)ការធ្វើឱ្យប្រសើរឡើងនៃបច្ចេកវិទ្យាឌីជីថលសម្រាប់សុខភាពមាត់ធ្មេញ។ យុទ្ធសាស្រ្តសកលស្តីពីសុខភាពមាត់ធ្មេញ គឺផ្តោតលើទស្សនៈវិស័យដែលមនុស្សទាំងអស់អាចមានលទ្ធភាពទទួលបានសេវាគ្របដណ្តប់សុខភាពមាត់ធ្មេញជាសកលនៅឆ្នាំ២០៣០។

ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញនៅកម្ពុជា បានយកលំនាំតាមការចង្អុលបង្ហាញដោយយុទ្ធសាស្រ្តសកលសម្រាប់សុខភាពមាត់ធ្មេញនោះ ហើយក៏អនុលោមស្របតាមមាគ៌ានៃគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។

### ១.១.១-ផែនការសកម្មភាពសុខភាពមាត់ធ្មេញសកលឆ្នាំ២០២៣-២០៣០

ផែនការសកម្មភាពសុខភាពមាត់ធ្មេញសកល២០២៣-២០៣០ ត្រូវបានអនុម័តដោយអង្គការសុខភាពពិភពលោកនៅក្នុងខែឧសភាឆ្នាំ២០២៣ ដោយបានលើកឡើងនូវគោលដៅសំខាន់ៗចំនួនប្រាំមួយនិងចំណុចដៅសកលសំខាន់ចំនួនពីរ។ គោលដៅសំខាន់ៗចំនួនប្រាំមួយទាំងនោះរួមមាន៖ អភិបាលកិច្ចផ្នែកសុខភាពមាត់ធ្មេញ ការលើកកម្ពស់និងការពារជំងឺមាត់ធ្មេញ កម្លាំងធនធានមនុស្សផ្នែកទន្តសាស្ត្រ ការថែទាំសុខភាពមាត់ធ្មេញបឋម ប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្នែកសុខភាពមាត់ធ្មេញ និងរបៀបវារៈនៃការសិក្សាស្រាវជ្រាវផ្នែកសុខភាពមាត់ធ្មេញ។ ចំពោះចំណុចដៅទីមួយ គឺផ្តោតលើការគ្របដណ្តប់សុខភាពជាសកលសម្រាប់សុខភាពមាត់ធ្មេញ រីឯចំណុចដៅទីពីរគឺដើម្បីអាចសម្រេចបាននូវការកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃជំងឺមាត់ធ្មេញចម្បងៗប្រមាណ១០% និងធ្វើឱ្យសុខភាពមាត់ធ្មេញប្រសើរឡើងពេញមួយជីវិត[២]។

ផែនការសកម្មភាពសុខភាពមាត់ធ្មេញជាសកលនេះ បានលើកឡើងនូវសកម្មភាពចម្បងៗដែលអាចអនុវត្តបានចំនួន១០០សម្រាប់ប្រទេសជាសមាជិក លេខាធិការដ្ឋាននៃអង្គការសុខភាពពិភពលោក ដៃគូអន្តរជាតិ អង្គការសង្គមស៊ីវិល រួមទាំងវិស័យឯកជនផងដែរ លើគោលដៅយុទ្ធសាស្ត្រចំនួនប្រាំមួយ។ អង្គការសុខភាពពិភពលោកបានកំណត់ឱ្យសមាជិកទាំងអស់ធ្វើការរាយការណ៍ទៅលើសូចនាករទាំង១១ សម្រាប់ធ្វើការតាមដានវាយតម្លៃនិងត្រួតពិនិត្យលើវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពសុខភាពមាត់ធ្មេញជាសកលនេះ រៀងរាល់បីឆ្នាំម្តង ដោយត្រូវផ្តល់របាយការណ៍ជាមូលដ្ឋានចាប់ផ្តើមពីឆ្នាំ២០២៤។

### ១.១.២-ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការពារនិងប្រយុទ្ធនឹងជំងឺមិនឆ្លង២០២២-២០៣០

សុខភាពមាត់ធ្មេញត្រូវបានទទួលស្គាល់ដោយក្រសួងសុខាភិបាលនៃប្រទេសកម្ពុជាថា ជាផ្នែកមួយដ៏មានសារៈសំខាន់នៃសុខភាពសាធារណៈ ដែលមានលើកឡើងនៅក្នុងគោលដៅយុទ្ធសាស្ត្រទី២ នៃផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការពារនិងប្រយុទ្ធនឹងជំងឺមិនឆ្លង២០២២-២០៣០របស់ប្រទេសកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំជាផែនការសកម្មភាពជាតិរយៈពេលវែងសម្រាប់ផ្នែកសុខភាពមាត់ធ្មេញ[៣]។ គោលដៅយុទ្ធសាស្ត្រទី២នោះ គឺផ្តោតលើការរៀបចំប្រព័ន្ធសុខាភិបាល ដើម្បីផ្តល់សេវាផ្នែកជំងឺមិនឆ្លងរួមមានទាំងផ្នែកសុខភាពមាត់ធ្មេញផង តាមរយៈការថែទាំសុខភាពបឋមដែលផ្តោតលើប្រជាជនជាគោល ការគ្របដណ្តប់សុខភាពជាសកល និងការគាំទ្រសម្រាប់ការគ្រប់គ្រងជំងឺរ៉ាំរ៉ៃនានា។ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការពារនិងប្រយុទ្ធនឹងជំងឺមិនឆ្លង បានណែនាំឱ្យមានវិធានការរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាពខ្ពស់និង

មធ្យោបាយពីដើមទី ដើម្បីទប់ស្កាត់នូវកត្តាហានិភ័យផ្សេងៗដែលបង្កជំងឺរ៉ាំរ៉ៃនានារួមមាន ការប្រើប្រាស់ថ្នាំជក់ ការប្រើប្រាស់គ្រឿងស្រវឹងប្រកបដោយគ្រោះថ្នាក់ របបអាហារមិនល្អចំពោះសុខភាព និងកង្វះការធ្វើកាយវប្បកម្ម។

ទាក់ទងនឹងផ្នែកសុខភាពមាត់ធ្មេញ នៅក្នុងផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការពារនិងប្រយុទ្ធនឹងជំងឺមិនឆ្លង២០២២-២០៣០បានចែងថា៖ (១)ការបង្ការនិងការពារសុខភាពមាត់ធ្មេញសម្រាប់ក្រុមកុមារដោយប្រើប្រាស់សារជាតុភ្លុយអរ៉ាយលាបផ្ទាល់ (រួមមានទាំងសារជាតុភ្លុយអរ៉ាយវ៉ានីសសម្រាប់លាបការពារជំងឺពុកធ្មេញនិងសារជាតុSDFលាបទប់ស្កាត់ការរីករាលដាលជំងឺពុកធ្មេញ) (២)ដាក់បញ្ចូលការងារថែទាំសុខភាពមាត់ធ្មេញជាមួយនឹងសកម្មភាពប្រយុទ្ធនឹងជំងឺមិនឆ្លង (៣)ការបង្កើតភស្តុតាងបង្ហាញសម្រាប់ការថែទាំជំងឺមាត់ធ្មេញក្នុងចំណោមមនុស្សពេញវ័យនិងមនុស្សចាស់ ដោយរួមទាំងការបង្ការនិងការស្រាវជ្រាវរកជំងឺមហារីកប្រអប់មាត់បានទាន់ពេលផងដែរ។ បញ្ហាមាត់ធ្មេញដែលបានរៀបរាប់ខាងលើ ត្រូវបានកំណត់រួចហើយនៅក្នុងសំណុំសកម្មភាពអប្បបរមា(MPA)សម្រាប់មណ្ឌលសុខភាព និងសំណុំសកម្មភាពបង្គ្រប់(CPA)សម្រាប់មន្ទីរពេទ្យបង្អែក ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែងនៃសកម្មភាពអន្តរាគមន៍ទាំងនោះនៅមានកម្រិតនៅឡើយ។ ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញនេះ មានគោលបំណងផ្តល់ជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តសកម្មភាពនានាដែលទាក់ទងទៅនឹងផ្នែកសុខភាពមាត់ធ្មេញ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការពារនិងប្រយុទ្ធនឹងជំងឺមិនឆ្លង២០២២-២០៣០។

### ១.១.៣- គោលការណ៍ណែនាំស្តីពីការលើកកម្ពស់និងការត្រួតពិនិត្យការលូតលាស់សម្រាប់កុមារអាយុក្រោម៥ឆ្នាំនៅកម្ពុជា

សុខភាពមាត់ធ្មេញ ត្រូវបានចាត់ទុកជាផ្នែកមួយដ៏សំខាន់នៃការលូតលាស់និងការអភិវឌ្ឍនៃរាងកាយជាទូទៅសម្រាប់កុមារអាយុក្រោម៥ឆ្នាំ។ គោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យការលូតលាស់រាងកាយកុមារអាយុក្រោម៥ឆ្នាំ របស់មជ្ឈមណ្ឌលគាំពារមាតានិងទារកក្នុងប្រទេសកម្ពុជានៃក្រសួងសុខាភិបាល(៤) បានបង្ហាញអំពីពេលវេលាសំខាន់ៗសម្រាប់កុមារចាំបាច់ក្នុងការទទួលបាននូវការប្រឹក្សា ផ្នែកអាហារូបត្ថម្ភ ការចាក់វ៉ាក់សាំងបង្ការជំងឺ ការបន្ថែមវីតាមីនអា និងទទួលថ្នាំទម្លាក់ជង្គរព្រូន។ យោងតាមការស្ទង់មតិប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០២១-២០២២បានបង្ហាញថា ជាង៨៥%នៃស្ត្រីមានផ្ទៃពោះទទួលបានការថែទាំមុនពេលសម្រាល ហើយ៧៦%នៃកុមារបានទទួលការចាក់វ៉ាក់សាំង ដែលបង្ហាញពីអត្រាខ្ពស់នៃការផ្តល់ថ្នាំ

បង្ការ[៥]។ ការផ្តល់សេវាផ្នែកលើកកម្ពស់សុខភាពមាត់ធ្មេញនិងការការពាររោគពុកធ្មេញ គួរត្រូវបានដាក់បញ្ចូលទៅក្នុងតារាងកាលវិភាគដែលបានកំណត់ ដើម្បីជាចំណែកមួយនៃការលើកកម្ពស់ការលូតលាស់រាងកាយទូទៅរបស់កុមារ។

### ១.១.៤- ផែនការសកម្មភាពជាតិស្តីពីសុខភាពសិក្សាឆ្នាំ២០២១-២០៣០

ជំងឺមាត់ធ្មេញ ត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានសុខភាពសិក្សាថាជាបញ្ហាចម្បងមួយសម្រាប់កុមារនៅកម្រិតមត្តេយ្យសិក្សានិងបឋមសិក្សា ដោយសារមានកុមារចំនួន៩នាក់ក្នុងចំណោម១០នាក់មានជំងឺពុកធ្មេញ[៦]។ ផែនការសកម្មភាពនេះបានបង្ហាញពីការរំពឹងទុកលើសកម្មភាពអនុវត្តន៍ការដុសធ្មេញជាក្រុមប្រចាំថ្ងៃនៅតាមសាលារៀន រួមទាំងលើកឡើងពីគោលបំណងនៃការធ្វើការពិនិត្យសុខភាពមាត់ធ្មេញប្រចាំឆ្នាំ និងការព្យាបាលធ្មេញនៅក្នុងបរិយាកាសសាលារៀន។ ក្នុងនោះដែរ ក៏មានការទទួលស្គាល់នូវកត្តាហានិភ័យទូទៅសម្រាប់ជំងឺមិនឆ្លង និងតម្រូវការក្នុងការចាត់វិធានការជុំវិញការហាមឃាត់ការប្រើប្រាស់ផលិតផលថ្នាំជក់ ការប្រើប្រាស់គ្រឿងស្រវឹងប្រកបដោយគ្រោះថ្នាក់ របបអាហារមិនល្អចំពោះសុខភាព និងកង្វះការធ្វើកាយវប្បកម្ម។ កត្តាដែលសំខាន់ម្យ៉ាងទៀតនោះ គឺការលក់អាហារសម្រន់ដែលមានជាតិស្ករនិងភេសជ្ជៈផ្អែម ត្រូវបានហាមឃាត់នៅក្នុងបរិវេណសាលារៀន។

## ១.២- ស្ថានភាព

### ១.២.១. ស្ថានភាពសុខភាពមាត់ធ្មេញនៅក្នុងប្រទេសកម្ពុជា

នៅក្នុងប្រទេសកម្ពុជា សូចនាករនៃសុខភាពទូទៅភាគច្រើនមានភាពល្អប្រសើរ ដោយអត្រានៃភាពស្គមស្គាំងធ្ងន់ធ្ងរក្នុងចំណោមកុមារតូចនិងអត្រាមរណៈរបស់ទារកបានធ្លាក់ចុះ ប៉ុន្តែបែរជាមានការកើនឡើងនូវអាត្រានៃកុមារដែលមានបញ្ហាមាត់ធ្មេញទៅវិញ។

ការសិក្សាអង្កេតសុខភាពមាត់ធ្មេញថ្នាក់ជាតិឆ្នាំ២០១១ បង្ហាញថាប្រមាណ៩៣%នៃកុមារអាយុ៦ឆ្នាំមានធ្មេញពុកខូច ដោយគិតជាមធ្យមក្នុងកុមារម្នាក់មានធ្មេញទឹកដោះចំនួន៩ធ្មេញពុកខូច ហើយក្នុងនោះប្រមាណជា៦៥%នៃកុមារទាំងនោះ មានធ្មេញមួយឬច្រើនដែលពុកចូលដល់បណ្តូលធ្មេញ ឬមានការបង្ករោគ (ប្រើការវាស់វែងដោយ PUFA index)[៧]។

យោងទៅតាមការប្រៀបធៀបនៃការសិក្សាអង្កេតសុខភាពមាត់ធ្មេញថ្នាក់ជាតិចំនួនពីរលើក ដែលបានធ្វើឡើងក្នុងឆ្នាំ១៩៩០និង២០១១ បានបញ្ជាក់ច្បាស់ថាជំងឺមាត់ធ្មេញមានការកើនឡើង។ លទ្ធផលការសិក្សាអង្កេតនៅឆ្នាំ១៩៩០ ក្រុមកុមារអាយុ១២ឆ្នាំជាមធ្យមកុមារម្នាក់គឺមានធ្មេញពុកខូច(DMFT index) ចំនួន១.៦ ផ្ទុយទៅវិញលទ្ធផលនៃការសិក្សានាឆ្នាំ២០១១បានបង្ហាញថា ជំងឺពុកធ្មេញនៃក្រុមកុមារអាយុ១២ឆ្នាំ បានកើនឡើងទ្វេដងដោយក្នុងកុមារម្នាក់គិតជាមធ្យមមានធ្មេញពុកខូចក្នុងមាត់ចំនួន៣.៥[៨]។

លើសពីនេះទៅទៀត ជំងឺពុកធ្មេញត្រូវបានរកឃើញថាមានទំនាក់ទំនងគ្នាជាមួយនឹងភាពក្រិនស្គមស្គាំងនិងកង្វះអាហារូបត្ថម្ភរបស់កុមារតូច(អាយុក្រោម៦ឆ្នាំ)[៩,១០] ហើយជំងឺពុកធ្មេញនេះបង្កឱ្យមានផលប៉ះពាល់ដល់គុណភាពនៃជីវិតនិងការរស់នៅរបស់ពួកគេយ៉ាងច្រើន[១១]។ ការព្យាបាលនៃជំងឺមាត់ធ្មេញគួរតែត្រូវបានព្យាបាល ដើម្បីកាត់បន្ថយទាំងការឈឺចាប់និងភាពរំខាន និងដើម្បីការពារផលប៉ះពាល់ផ្សេងៗទៀត ជាពិសេសលើការលូតលាស់និងការអភិវឌ្ឍរាងកាយរបស់កុមារ ដែលនេះជាផ្នែកមួយនៃការថែទាំសុខភាពតាមវិធីសាស្ត្រផ្តោតលើមនុស្សជាគោល។

សុខភាពនិងជំងឺមាត់ធ្មេញ មិនគួរត្រូវបានកំណត់ត្រឹមតែការគ្រប់គ្រងលើជំងឺពុកធ្មេញប៉ុណ្ណោះទេ។ តាមការប៉ាន់ស្មានបានបង្ហាញថា មនុស្សពេញវ័យក្នុងប្រទេសកម្ពុជា១នាក់ក្នុងចំណោម៣នាក់ មានអញ្ចាញធ្មេញ(ជាលិកាទ្រទ្រង់ធ្មេញ)ប្រកបដោយសុខភាពល្អ។ លទ្ធផលនៃការសិក្សាអង្កេតសុខភាពមាត់ធ្មេញថ្នាក់ជាតិឆ្នាំ២០១១បានបង្ហាញថា ប្រមាណ២០%នៃមនុស្សចាស់អាយុលើសពី៦០ឆ្នាំមានរោគសញ្ញាដំបូងនៃជំងឺរលាកជាលិកាទ្រទ្រង់ធ្មេញ(មានថង់អញ្ចាញរាក់៤-៥mm) និង១៤%ទៀតមានរោគសញ្ញាជំងឺរលាកជាលិកាទ្រទ្រង់ធ្មេញខ្លាំង(មានថង់អញ្ចាញជ្រៅ>៦mm)។ ការសិក្សានេះក៏បានបង្ហាញថា ៣២%នៃមនុស្សចាស់អាយុលើសពី៦០ឆ្នាំ មានតម្រូវការធ្មេញពាក់(ដាក់ដោះ)មួយផ្នែក ហើយប្រមាណ១៧%ទៀតមានតម្រូវការធ្មេញស្និតពាក់យ៉ាងហោចណាស់មួយក្រាស។ ការបាត់បង់ធ្មេញភាគច្រើន គឺបណ្តាលមកពីជំងឺពុកធ្មេញនិងជំងឺអញ្ចាញធ្មេញ ដូច្នេះហើយបានជាមនុស្សចាស់មានផលប៉ះពាល់យ៉ាងច្រើនក្នុងជីវិតចុងក្រោយ ជាពិសេសដល់សមត្ថភាពទំពាអាហារនិងគុណភាពជីវិតរបស់ពួកគាត់[១២]។ អត្រាប្រេវ៉ាឡង់អ្នកដែលបាត់បង់ធ្មេញទាំងអស់ក្នុងមាត់ ក្នុងចំណោមមនុស្សពេញវ័យ(អាយុលើសពី២០ឆ្នាំ)ក្នុងប្រទេសកម្ពុជា គឺមានចំនួនប្រមាណ៥%[១៣]។ រីឯក្នុងចំណោមមនុស្សចាស់វ័យលើសពី៦០ឆ្នាំ មានការប៉ាន់ប្រមាណថា ម្នាក់ក្នុងចំណោម៥នាក់បាត់បង់ធ្មេញទាំងអស់ក្នុងមាត់ ប៉ុន្តែមានតែមួយភាគបួននៃអ្នកទាំងនោះដែលបានធ្វើធ្មេញស្និតពាក់[១៣]។

បញ្ហាសុខភាពមាត់ធ្មេញដ៏សំខាន់មួយទៀតគឺជំងឺមហារីកប្រអប់មាត់ ដែលភាគច្រើនទាក់ទងនឹងទម្លាប់ជក់បារីនិងទំពាម្លូស្លា។ យោងតាមទិន្នន័យរបស់អង្គការសុខភាពពិភពលោក ដែលបានចេញផ្សាយក្នុងឆ្នាំ២០២០ មានអ្នកស្លាប់៦៧១នាក់ដោយសារជំងឺមហារីកប្រអប់មាត់-បំពង់ក(oropharyngeal) និងឆ្អឹងថ្គាម ក្នុងនោះរួមមានមហារីកបបូរមាត់និងប្រអប់មាត់៣០៨នាក់ Nasopharynx (២១៥នាក់) ក្រពេញទឹកមាត់២៧នាក់ Oropharynx (៦៣នាក់) និង Hypopharynx (៥៨នាក់) [១៤,១៥]។

ការការពារនិងគ្រប់គ្រងជំងឺមាត់ធ្មេញ គួរតែត្រូវបានពិចារណាលើកត្តាបង្កហានិភ័យទូទៅចំនួនបីគឺការប្រើប្រាស់ស្ករ ការប្រើប្រាស់ថ្នាំជក់ និងការប្រើប្រាស់គ្រឿងស្រវឹង។ នៅក្នុងប្រទេសកម្ពុជា មានការប៉ាន់ប្រមាណថា មនុស្សម្នាក់ប្រើប្រាស់ជាតិស្ករប្រមាណ៧៣,២ក្រាមក្នុងមួយថ្ងៃ[១៣] ហើយទិន្នន័យក្នុងស្រុកក៏បានបង្ហាញថា ការប្រើប្រាស់ជាតិស្ករខ្ពស់ជាង៥០%ក្នុងចំណោមសិស្សសាលា[១៦]។ ការប្រើប្រាស់ជាតិស្ករច្រើន គឺជាឧទាហរណ៍ពន្យល់យ៉ាងច្បាស់ថា ដែលជាមូលហេតុនៃការកើនឡើងនៃជំងឺមាត់ធ្មេញ។ តាមការសិក្សាមានមនុស្សពេញវ័យកម្ពុជាម្នាក់ក្នុងចំណោមប្រាំនាក់ប្រើប្រាស់ថ្នាំជក់ ហើយម្នាក់ក្នុងចំណោមដប់នាក់ប្រើប្រាស់គ្រឿងស្រវឹង[១៣]។

ផែនការសកម្មភាពសុខភាពមាត់ធ្មេញសកល២០២៣-២០៣០បានទទួលស្គាល់ថា ជំងឺមាត់ធ្មេញទទួលឥទ្ធិពលដោយកត្តាសង្គមនិងការផ្សព្វផ្សាយពាណិជ្ជកម្មទាក់ទងនឹងសុខភាព[២]។ កត្តាសង្គម រួមមានសង្គមបរិយាកាស សេដ្ឋកិច្ច និងនយោបាយ មានឥទ្ធិពលលើសុខភាពមាត់ធ្មេញ ដែលក្នុងនោះទាក់ទងនឹងការទទួលបានទឹកស្អាត ការរស់នៅស្អាត និងអនាម័យ។ ការផ្សព្វផ្សាយពាណិជ្ជកម្ម គឺជាយុទ្ធសាស្ត្ររបស់វិស័យឯកជនមួយចំនួនប្រើក្នុងការផ្សព្វផ្សាយផលិតផល ដែលបណ្ដាលឱ្យមានផលប៉ះពាល់ដល់សុខភាព។

### ១.២.២. កម្លាំងធនធានមនុស្សផ្នែកទន្តសាស្ត្រនៅកម្ពុជា

ការថែទាំសុខភាពសាធារណៈគឺស្ថិតនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ការិយាល័យសុខភាពមាត់ធ្មេញដែលស្ថិតនៅក្នុងនាយកដ្ឋានការពារសុខភាពនៃទីស្ដីការក្រសួង ជាទីតាំងតំណាងឱ្យផ្នែកទន្តសាស្ត្រនៅថ្នាក់ជាតិ មានភារកិច្ចទទួលបន្ទុកក្នុងការផ្ដល់ការណែនាំផ្នែកបច្ចេកទេសដល់អ្នកផ្ដល់សេវាថែទាំសុខភាពសាធារណៈទាក់ទងនឹងផ្នែកសុខភាពមាត់ធ្មេញ។ ការិយាល័យសុខភាពមាត់ធ្មេញ មានភារកិច្ចក្នុងការបង្កើតជាគោលនយោបាយនិងយុទ្ធសាស្ត្រជាតិទាក់ទងផ្នែកសុខភាពមាត់ធ្មេញ សម្របសម្រួលកម្មវិធីលើកកម្ពស់និងការថែទាំសុខភាពមាត់ធ្មេញ សកម្មភាពតាមដានត្រួតពិនិត្យសុខភាព រួមទាំងការសិក្សាអង្កេតស្រាវជ្រាវ

និងការផ្តល់ការគាំទ្រដល់មន្ត្រីផ្នែកសុខភាពមាត់ធ្មេញសាធារណៈ តាមរយៈការបណ្តុះបណ្តាលបន្ត ដើម្បីផ្តល់នូវការថែទាំព្យាបាលមានលក្ខណៈស្តង់ដារនិងប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្រៅពីសកម្មភាពស្នូលទាំងនេះ ការិយាល័យសុខភាពមាត់ធ្មេញ ក៏បានចូលរួមក្នុងការបង្កើតនិងធ្វើបច្ចុប្បន្នភាពឯកសារគោលនយោបាយនានា ដែលទាក់ទងនឹងសុខភាពមាត់ធ្មេញជាមួយស្ថាប័ន/អង្គភាពពាក់ព័ន្ធ រួមទាំងកម្មវិធីសិក្សានានា ដើម្បីកសាងនិងពង្រឹងសមត្ថភាពក្នុងការបង្កើតកម្លាំងធនធានមនុស្សផ្នែកទន្តសាស្ត្រនៅកម្ពុជា។

នៅថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកជាស្រុកប្រតិបត្តិចំនួន១០៣ និង១២៥០មណ្ឌលសុខភាពសម្រាប់ផ្តល់ការថែទាំសុខភាពដល់ប្រជាជនក្នុងសហគមន៍ តាមរយៈសំណុំសកម្មភាពអប្បបរមា(MPA)និងមន្ទីរពេទ្យបង្អែកដែលផ្តល់ការថែទាំតាមរយៈសំណុំសកម្មភាពបង្គ្រប់(CPA)។ គោលការណ៍ណែនាំរបស់សំណុំសកម្មភាពបង្គ្រប់បានចែងថា នៅតាមមន្ទីរពេទ្យបង្អែកចាំបាច់មានមន្ត្រីផ្នែកទន្តសាស្ត្រជាទន្តបណ្ឌិតមួយឬពីរនាក់ រីឯគោលការណ៍ណែនាំរបស់សំណុំសកម្មភាពអប្បបរមាបានចែងថា នៅតាមមណ្ឌលសុខភាពនីមួយៗត្រូវមានទន្តគិលានុបដ្ឋាកមួយនាក់ ដើម្បីអាចផ្តល់កញ្ចប់ថែទាំសុខភាពមាត់ធ្មេញបឋម[១៧]។

អ្នកប្រកបវិជ្ជាជីវៈផ្នែកទន្តសាស្ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលរួមមាន៖ ទន្តបណ្ឌិតឯកទេស ទន្តបណ្ឌិត/ទន្តពេទ្យ និងទន្តគិលានុបដ្ឋាក ដែលវិសាលភាពនៃការអនុវត្ត គឺស្របតាមឯកសារដែនកំណត់វិជ្ជាជីវៈ ឯកសារបទដ្ឋាន និងនិយាមវិជ្ជាជីវៈនៃការប្រតិបត្តិនៅកម្ពុជា។ យោងតាមស្ថិតិក្នុងឆ្នាំ២០២០ មានទន្តបណ្ឌិត/ទន្តពេទ្យបានចុះឈ្មោះក្នុងបញ្ជីរបស់គណៈទន្តពេទ្យចំនួន១៩១៦នាក់ ដែលពួកគាត់បានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សាចំនួន៥(សាលារដ្ឋចំនួន២និងឯកជនចំនួន៣)។ លើសពីនេះថែមទៀត ក៏មានទន្តបណ្ឌិតចំនួន១៤នាក់ ដែលបានត្រលប់មកពីសិក្សានៅក្រៅប្រទេស។

ចំណែកទន្តគិលានុបដ្ឋាកវិញ គឺជាអ្នកដែលបានបញ្ចប់សញ្ញាបត្របរិញ្ញាបត្ររងរយៈពេល៣ឆ្នាំ មានភារកិច្ចចម្បងលើការផ្តល់សេវាមាត់ធ្មេញបឋម ដោយផ្តោតទៅលើការអនុវត្តការលើកកម្ពស់សុខភាពមាត់ធ្មេញ ការការពារជំងឺមាត់ធ្មេញដោយប្រើប្រាស់សារធាតុភ្លុយអរ៉ាយលាបលើធ្មេញ ការលាបSDFទប់ស្កាត់ការរីករាលដាលនៃជំងឺពុកធ្មេញ ការព្យាបាលបិទប៉ះធ្មេញដោយប្រើបច្ចេកទេសART ការបិទការពារចង្អូរធ្មេញថ្គាម និងការព្យាបាលករណីបន្ទាន់(ការដកធ្មេញសាមញ្ញទាំងធ្មេញទឹកដោះនិងធ្មេញអចិន្ត្រៃយ៍ ការផ្តល់ឱសថបំបាត់ការឈឺចាប់ និងគ្រប់គ្រងការបង្ករោគ)។ នៅចន្លោះឆ្នាំ២០១០ដល់ឆ្នាំ២០២០ មានទន្តគិលានុបដ្ឋាកចំនួន៧០៦នាក់ បានបញ្ចប់ការសិក្សាពីសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគពីរ គឺនៅខេត្តកំពង់ចាម

ចំនួន៨៥៥នាក់ ខេត្តកំពតចំនួន១៧នាក់ និងតាមសាកលវិទ្យាល័យឯកជនចំនួន៣ផ្សេងទៀតចំនួន២៣៤នាក់។

ការបែងចែកកម្លាំងធនធានមនុស្សផ្នែកទន្តសាស្ត្រនៅមិនទាន់បានល្អនៅឡើយ ដោយមានគម្លាតរវាងកម្លាំងធនធានមនុស្ស រចនាសម្ព័ន្ធនៃការផ្តល់សេវា និងតម្រូវការនៃការថែទាំសុខភាពមាត់ធ្មេញរបស់ប្រជាជន ជាហេតុបណ្តាលឱ្យមានកង្វះខាតការគ្របដណ្តប់សុខភាពមាត់ធ្មេញជាសកល(១៧)។ បច្ចុប្បន្ននេះមានទន្តបណ្ឌិត/ទន្តពេទ្យចំនួន៣៣២នាក់និងទន្តគិលានុបដ្ឋាកចំនួន១៦៨នាក់ កំពុងបម្រើការងារជាមន្ត្រីក្របខណ្ឌសាធារណៈ នៅតាមមន្ទីរពេទ្យនិងមណ្ឌលសុខភាពទូទាំងប្រទេសកម្ពុជា។ ទន្តបណ្ឌិត/ ទន្តពេទ្យ និងទន្តគិលានុបដ្ឋាកដែលបានបញ្ចប់ការសិក្សាភាគច្រើនធ្វើការក្នុងវិស័យឯកជន ហើយមួយចំនួនទៀតធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល។

## ១.៣- បញ្ហាអាទិភាព

ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញ២០២៣-២០៣០ បានលើកឡើងនូវបញ្ហាជាអាទិភាពចំនួនប្រាំមួយ ដែលត្រូវស្វែងរកដំណោះស្រាយ ស្របតាមគោលការណ៍ណែនាំនៃផែនការសកម្មភាពសុខភាពមាត់ធ្មេញសកល(១៨) ដើម្បីអាចផ្តល់អត្ថប្រយោជន៍ផ្នែកសុខភាពមាត់ធ្មេញជូនដល់ប្រជាជនបានច្រើនបំផុត តាមរយៈកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់សុខភាពមាត់ធ្មេញ និងវិធានការអន្តរាគមន៍ទប់ស្កាត់ដើមទី។

### ១.៣.១- បញ្ហាអាទិភាព៖ សុខភាពមាត់ធ្មេញមានអាទិភាពតិចតួច

បញ្ហាប្រឈមចម្បងសម្រាប់ផ្នែកសុខភាពមាត់ធ្មេញ គឺការកំណត់ជាអាទិភាពនិងការផ្តល់ថវិកា។ បច្ចុប្បន្ននេះ ទោះបីជាបញ្ហាមាត់ធ្មេញកើតមានច្រើនក្នុងចំណោមប្រជាជនកម្ពុជាក៏ដោយ ក៏ផ្នែកសុខភាពមាត់ធ្មេញ ត្រូវបានផ្នែកដទៃៗទៀតនៅក្នុងក្រសួងសុខាភិបាលនិងស្ថាប័នផ្សេងៗ ចាត់ទុកថាជាវិស័យមានអាទិភាពទាប។ រីឯការលើកផែនការថវិកានៃការចំណាយលើការផ្តល់សេវានានា ក៏ត្រូវបានធ្វើវិមជ្ឈការដល់ថ្នាក់ក្រោមជាតិដែលជាហេតុនាំឱ្យបញ្ហាសុខភាពមាត់ធ្មេញត្រូវបានមើលរំលង។ ចំណែកឯតួនាទីរបស់ការិយាល័យសុខភាពមាត់ធ្មេញ ត្រូវបានកំណត់ត្រឹមតែការផ្តល់ប្រឹក្សាបច្ចេកទេស ការបណ្តុះបណ្តាលបន្តការធ្វើអភិបាលកិច្ចគ្រប់គ្រង តែមិនមានឥទ្ធិពលលើផ្នែកថវិកាសម្រាប់ប្រតិបត្តិការថ្នាក់ក្រោមជាតិឡើយ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ ចំណុចដ៏សំខាន់គឺការបញ្ចុះបញ្ចូលរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលដែលជាប្រភពផ្តល់ថវិកាឱ្យយល់ថា ផ្នែកសុខភាពមាត់ធ្មេញគួរតែត្រូវបានចាត់ជាអាទិភាពសម្រាប់ការចំណាយនិងទទួលបាននូវការគាំទ្រ។ កន្លងមក ផ្នែកតាមឯកសារផែនការយុទ្ធសាស្ត្រមេនិងគោលនយោបាយសុខភាពមាត់ធ្មេញដែលបានរៀបចំស្រាប់ មិនមានឥទ្ធិពលគ្រប់គ្រាន់លើគោលនយោបាយរបស់ថ្នាក់លើ ឬទទួលបានការទាក់ទាញក្នុងការផ្តល់ថវិកាសមស្របនោះទេ។ ដូចនេះ ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញនិងនវានុវត្តន៍ជាយុទ្ធសាស្ត្រថ្មី គឺត្រូវធ្វើឡើងដើម្បីទាក់ទាញការគាំទ្រនិងលើកស្ទួយផ្នែកសុខភាពមាត់ធ្មេញ ឱ្យមានការទទួលស្គាល់កម្រិតខ្ពស់បំផុតពីថ្នាក់ក្រសួង។

### ១.៣.២- បញ្ហាអាទិភាព៖ ធនធានមនុស្សមិនសមស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ

ទោះបីជាមានរចនាសម្ព័ន្ធចាត់តាំងផ្នែកទន្តសាស្ត្រតាមមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាពហើយក៏ដោយ ប៉ុន្តែធនធានមនុស្សផ្នែកទន្តសាស្ត្រនៅតែប្រឈមមុខនឹងបញ្ហាមួយចំនួន ដូចជាកង្វះធនធានមនុស្សនិងការបែងចែកកម្លាំងមិនទាន់បានសមស្របនៅឡើយ។ រីឯធនធានមនុស្សនិងការផ្តល់សេវាផ្នែកទន្តសាស្ត្រភាគច្រើន មានតែនៅតាមទីប្រជុំជនធំៗ និងនៅតាមមន្ទីរពេទ្យបង្អែកមួយចំនួនប៉ុណ្ណោះ។ ដំណោះស្រាយដ៏ប្រសើរសម្រាប់បញ្ហានេះ គឺត្រូវការបណ្តុះបណ្តាលបន្ថែម ដល់អ្នកផ្តល់សេវាសុខាភិបាលដទៃទៀត(ដែលមិនមែនជាអ្នកជំនាញផ្នែកទន្តសាស្ត្រ) ដើម្បីឱ្យពួកគាត់អាចអនុវត្តបាននូវសេវាថែទាំការពារសុខភាពមាត់ធ្មេញមួយចំនួន។ ឧបសគ្គមួយក្នុងចំណោមឧបសគ្គនានានៃការផ្តល់សម្រាប់ការបណ្តុះបណ្តាលបែបនេះ គឺត្រូវការមាននូវកម្មវិធីបណ្តុះបណ្តាលនិងជំនាញជាក់លាក់ដើម្បីបណ្តុះបណ្តាលពួកគេ។

### ១.៣.៣- បញ្ហាអាទិភាព៖ ជំងឺពុកធ្មេញក្នុងចំណោមកុមារតូចក្នុងប្រទេសកម្ពុជា

នៅក្នុងប្រទេសកម្ពុជា ប្រមាណ៣ភាគ៤នៃកុមារតូចអាយុក្រោម៣ឆ្នាំមានជំងឺពុកធ្មេញ(៨៦%មានធ្មេញពុកខូចមួយឬច្រើន)[៧] ហើយមានតែមួយចំនួនតូចនៃកុមារដែលមានបញ្ហាទាំងនោះ ទទួលបានការថែទាំព្យាបាល។ ជាទូទៅ ក្រុមអាយុនេះតែងតែមានការភ័យខ្លាច ពិបាកនឹងទទួលការព្យាបាលធ្មេញដោយការប្រើប្រដាប់ខែវ៉ឬការចាក់ថ្នាំ ជាលទ្ធផលពួកគេតែងតែប្រឈមនឹងការឈឺចាប់ខ្លាំង ដែលធ្វើឱ្យមានការពិបាកក្នុងការញ៉ាំនិងពិបាកគេង(ទាំងកុមារផ្ទាល់និងសមាជិកក្រុមគ្រួសារ)។ ជាញឹកញយ ពួកគេត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិចក្នុងការទប់ស្កាត់ការបង្ករោគ ពីព្រោះតែមិនបានទទួលការថែទាំព្យាបាលធ្មេញបានត្រឹមត្រូវនិងជាប្រចាំ។ ក្រុមកុមារដែលមានធ្មេញពុកក្នុងមាត់ទាំងនោះ គឺច្រើនតែមានសភាពស្គមស្គាំងនិងរូបរាងក្រិនដោយសារកង្វះអាហារូបត្ថម្ភ[៧,៨]។

### ១.៣.៤ - បញ្ហាអាទិភាព៖ ជំងឺពុកធ្មេញក្នុងចំណោមសិស្សសាលាបឋមសិក្សា

ឯកសារយោងមួយចំនួនបានបញ្ជាក់ច្បាស់ថា កុមារដែលកំពុងសិក្សានៅតាមសាលារៀនក្នុងប្រទេសកម្ពុជាមានបញ្ហាពុកធ្មេញធ្ងន់ធ្ងរ។ ប្រមាណជាង៩៣% នៃសិស្សសាលាបឋមសិក្សាមានធ្មេញពុកខូចដោយគិតជាមធ្យមសម្រាប់កុមារអាយុ៦ឆ្នាំម្នាក់គឺមានធ្មេញពុកខូចចំនួន៩ធ្មេញ ហើយមានចំនួនកុមារតិចជាង៥%ប៉ុណ្ណោះ ដែលបានទទួលការព្យាបាលបិទប៉ះធ្មេញឡើងវិញ(៨)។ ពោគសញ្ញានៃជំងឺពុកធ្មេញទាំងនេះបង្កឱ្យមានការឈឺចាប់និងពិបាកក្នុងការបរិភោគ ព្រមទាំងមានផលប៉ះពាល់ដល់ការលូតលាស់និងសិក្សារៀនសូត្ររបស់កុមារ។ ការផ្លាស់ប្តូរពីធ្មេញទឹកដោះទៅធ្មេញអចិន្ត្រៃយ៍(ធ្មេញស្រុក) គឺកើតឡើងក្នុងអំឡុងពេលដែលពួកគេរៀននៅសាលាបឋមសិក្សា ដូចនេះទើបការថែទាំធ្មេញស្រុកបានល្អមិនពុកខូចនៅក្នុងវ័យនេះនឹងមានផលល្អដល់សុខភាពមាត់ធ្មេញពេលពួកគាត់ធំពេញវ័យ។ លើសពីនេះ ការដោះស្រាយនូវការឈឺចាប់និងបង្ករោគដោយសារបញ្ហាមាត់ធ្មេញទាំងឡាយបាន នឹងផ្តល់នូវអត្ថប្រយោជន៍យ៉ាងប្រសើរដល់ការសិក្សារៀនសូត្រនិងជីវិតរស់នៅពេញមួយជីវិត មិនត្រឹមតែសម្រាប់សុខភាពមាត់ធ្មេញប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចគ្រួសារផងដែរ។

វិធានការដ៏ងាយស្រួលនិងល្អប្រសើរក្នុងការកាត់បន្ថយរោគពុកធ្មេញរបស់កុមារកម្ពុជា គឺបង្កទម្លាប់ដុសសម្អាតធ្មេញជាប្រចាំថ្ងៃ។ នាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវស្តង់ដារអប្បបរមាទាក់ទងនឹងទឹកស្អាតនិងអនាម័យទូទៅក្នុងសាលារៀន ដែលមានការដុសសម្អាតធ្មេញផងដែរ(១៩)។ ទន្ទឹមនឹងនោះ ក៏មានការគាំទ្រយ៉ាងខ្លាំងចំពោះការកាត់បន្ថយការប្រើប្រាស់ជាតិស្ករ រួមមានទាំងការរឹតបន្តឹងលើការលក់ចំណីអាហារ និងភេសជ្ជៈដែលមិនល្អសម្រាប់សុខភាពនៅក្នុងបរិវេណសាលារៀន។ ទោះជាយ៉ាងនេះក្តី សកម្មភាពថែទាំសុខភាពមាត់ធ្មេញសម្រាប់កុមារតាមសាលារៀន នៅមានទ្រង់ទ្រាយតូចៗនៅឡើយ ដោយភាគច្រើនគឺធ្វើឡើងតាមរយៈអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ហើយមិនទាន់មានការរៀបចំជាកម្មវិធីគំរូ ក្នុងការដោះស្រាយរាល់បញ្ហាមាត់ធ្មេញសម្រាប់កុមារនៅឡើយ។ រីឯការថែទាំព្យាបាលមាត់ធ្មេញដោយប្រើឧបករណ៍សម្ភារៈទំនើបនិងប្រកបដោយបច្ចេកទេសខ្ពស់ ទំនងជាមិនទាន់អាចផ្តល់បានប្រកបដោយនិរន្តរភាពនៅក្នុងវិស័យសាធារណៈនៅក្នុងប្រទេសកម្ពុជា នាពេលអនាគតដ៏ខ្លីខាងមុខនោះទេ។ ការថែទាំបែបងាយៗ ដោយផ្តោតទៅលើសកម្មភាពបង្ការជំងឺនិងការព្យាបាលបែបសាមញ្ញ ដូចជាការលាប SDFការពារការរីករាលដាលរោគពុកធ្មេញនិងបិតប៉ះដោយបច្ចេកទេសART គឺមានសភាពសមស្របក្នុងការដោះស្រាយសម្រាប់បញ្ហាធ្មេញពុករបស់កុមារនៅតាមសាលារៀន។

### ១.៣.៥. បញ្ហាអាទិភាព៖ តម្រូវការការថែទាំសុខភាពមាត់ធ្មេញសម្រាប់មនុស្សចាស់

មនុស្សវ័យចំណាស់ គឺជាក្រុមអាយុដែលកំពុងមានការកើនឡើងនៅក្នុងចំណោមប្រជាជនកម្ពុជា។ នៅក្នុងឆ្នាំ២០១៩ ប្រជាជនកម្ពុជាដែលមានអាយុលើសពី៦០ឆ្នាំ មានប្រមាណជាង១,២លាននាក់ ដែលស្មើនឹង៨.៩%នៃចំនួនប្រជាជនសរុប[២០]។ ចំនួនសមាមាត្រនៃមនុស្សចាស់បានកើនឡើងប្រមាណ៤០% ចាប់តាំងពីជំរឿនដែលបានធ្វើឡើងក្នុងឆ្នាំ២០០៨ ហើយចំនួនមនុស្សចាស់ត្រូវបានគេរំពឹងថានឹងកើនឡើងជិតបីដងក្នុងទសវត្សរ៍ខាងមុខនេះ។ ក្រុមមនុស្សចាស់ដែលមានចំនួនកើនលឿនបំផុតគឺក្រុម "មនុស្សចាស់វ័យជរា" ឬអ្នកដែលមានអាយុពី៨០ឆ្នាំឡើង។

ការកើនឡើងនៃចំនួនមនុស្សចាស់នៅក្នុងចំណោមប្រជាជន មានផលប៉ះពាល់ដល់ការផ្តល់សេវាផ្នែកសុខភាព។ បច្ចុប្បន្ននេះ មិនទាន់មានការកំណត់បានច្បាស់លាស់លើ"កញ្ចប់នៃការថែទាំសុខភាព" សម្រាប់មនុស្សចាស់នោះទេ។ ការលើកកម្ពស់សុខភាពសម្រាប់មនុស្សចាស់ គឺជាគោលដៅចម្បងនៃគោលនយោបាយជាតិនិងយុទ្ធសាស្ត្រថែទាំសុខភាពសម្រាប់មនុស្សចាស់[២១] ហើយសុខភាពមាត់ធ្មេញគឺជាផ្នែកមួយដ៏សំខាន់មួយនៃសុខភាពមនុស្សចាស់ផងដែរ។

មនុស្សចាស់នៅកម្ពុជាភាគច្រើនមានស្ថានភាពសេដ្ឋកិច្ចទាប ហើយរស់នៅជាមួយក្រុមគ្រួសារនៅតាមតំបន់ជនបទ ដែលការមានការលំបាកក្នុងការទទួលបាននូវការថែទាំសុខភាពមាត់ធ្មេញ។ ការបង្កនូវលទ្ធភាពឱ្យទទួលបាននូវការគ្របដណ្តប់សុខភាពជាសកល និងការថែទាំព្យាបាលមាត់ធ្មេញប្រកបដោយស្តង់ដារខ្ពស់គួរត្រូវបានចាត់ជាអាទិភាព ពីព្រោះមនុស្សចាស់ដែលមានសុខភាពមាត់ធ្មេញមិនល្អ អាចមានផលប៉ះពាល់ជាអវិជ្ជមានដល់អាហារូបត្ថម្ភ មានការលំបាកក្នុងការបរិភោគអាហារ ដែលអាចជាកត្តាបង្កឱ្យសុខភាពរបស់ពួកគាត់កាន់តែមានសភាពទន់ខ្សោយ ហើយនិងប៉ះពាល់ដល់គុណភាពជីវិត។

### ១.៣.៦. បញ្ហាអាទិភាព៖ មហារីកប្រអប់មាត់ និងដំបៅក្នុងមាត់ដែលប្រឈមក្នុងការវិវត្តជាជំងឺមហារីក

ជំងឺមហារីកប្រអប់មាត់គឺជាបញ្ហាសុខភាពដ៏សំខាន់មួយទៀតនៅក្នុងប្រទេសកម្ពុជា។ លក្ខណៈពិសេសនៃជំងឺមហារីកប្រអប់មាត់ គឺមានការវិវត្តន៍យ៉ាងឆាប់រហ័ស ហើយមានអត្រាមរណភាពខ្ពស់។

យោងតាមទិន្នន័យរបស់អង្គការសុខភាពពិភពលោក ដែលធ្វើការសិក្សាស្រាវជ្រាវលើជំងឺមហារីក (IARC) ហៅកាត់ថា Globocan ក្នុងឆ្នាំ២០២០ ជំងឺមហារីកប្រអប់មាត់ គឺជាមហារីកមួយក្នុងចំណោមមហារីកដែលកើតមានជាទូទៅបំផុតទាំង១០ប្រភេទនៅក្នុងប្រទេសកម្ពុជា[១៤,១៥]។ បើទោះជាជំងឺមហារីក

ប្រអប់មាត់មានអត្រាប្រេវ៉ាឡង់ទាបជាងជំងឺមហារីកនៃសរីរាង្គដទៃទៀតក្តី តែមានអត្រាមរណភាពខ្ពស់ជាង ហើយក៏ជាបញ្ហាមួយដែលមនុស្សភាគច្រើនមិនបានយកចិត្តទុកដាក់ឡើយ ជាពិសេសក្នុងចំណោមបុគ្គលិកសុខាភិបាល។

នៅកម្ពុជា ការជក់បារីនិងការទំពាម្លូស្លា(ភាគច្រើនមនុស្សចាស់ស្ត្រី) គឺជាកត្តាហានិភ័យចម្បងពីរសំខាន់បំផុតដែលបង្កជំងឺមហារីកប្រអប់មាត់ ប៉ុន្តែគ្រឿងស្រវឹងក៏អាចធ្វើសកម្មភាពរួមគ្នាជាមួយថ្នាំជក់បង្កើនជាហានិភ័យនៃដំបៅក្នុងមាត់ដែលអាចប្រឈមជាមហារីកបាន(OPMDs) [២២]។

លក្ខណៈគួរឱ្យកត់សម្គាល់មួយទៀតគឺថា ជំងឺមហារីកប្រអប់មាត់មួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានគេរកឃើញនៅដំណាក់កាលដំបូង ជាហេតុនាំឱ្យការធ្វើរោគវិនិច្ឆ័យមានសភាពយឺតយ៉ាវ។ លើសពីនេះ មានកង្វះខាតនូវប្រព័ន្ធបញ្ជូនឱ្យបានចំទិសដៅ លទ្ធភាពក្នុងការទទួលបានការវះកាត់ និងវិធីសាស្ត្រផ្សេងៗទៀតក្នុងការព្យាបាលជំងឺមហារីក ជាពិសេសសម្រាប់ប្រជាជនកម្ពុជាដែលមានសេដ្ឋកិច្ចគ្រួសារទាបនិងរស់នៅតាមជនបទ។

## ២- គោលបំណង

គោលបំណងចម្បងនៃផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញ២០២៣-២០៣០ គឺដើម្បីបង្កើនលទ្ធភាពទទួលបាននូវការថែទាំសុខភាពមាត់ធ្មេញនិងកាត់បន្ថយជំងឺមាត់ធ្មេញនៅក្នុងចំណោមប្រជាជន។

ផែនការសកម្មភាពជាតិនេះ ដើរទន្ទឹមគ្នាជាមួយនឹងផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការពារនិងប្រយុទ្ធនឹងជំងឺមិនឆ្លង២០២៣-២០៣០។ ផែនការសកម្មភាពនេះ នឹងដំណើរការឆ្ពោះទៅរកការផ្តល់នូវសេវាសុខភាពមាត់ធ្មេញប្រកបដោយប្រសិទ្ធភាពនិងសមភាព ដើម្បីកាត់បន្ថយបន្ទុកនៃជំងឺមាត់ធ្មេញ ក៏ដូចជាបន្ធូរបន្ថយការឈឺចាប់ និងជួយដល់បន្ទុកសេដ្ឋកិច្ចគ្រួសារនិងសង្គម។

## ៣- យុទ្ធសាស្ត្រ

បញ្ហាអាទិភាពទាំងប្រាំមួយដែលបានលើកក្នុងឯកសារនេះ មានចំណុចខុសប្លែកពីផែនការជាតិសុខភាពមាត់ធ្មេញដែលបានរៀបចំពីពេលមុនៗ។ សំណុំសកម្មភាពបង្ការនិងសំណុំសកម្មភាពអប្បបរមាដែលបានរៀបចំឡើងក្នុងប្រព័ន្ធសេវាសុខភាពសាធារណៈ មានគោលបំណងដើម្បីសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល ដោយរួមបញ្ចូលទាំងការថែទាំសុខភាពមាត់ធ្មេញផងដែរ។

ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញ២០២៣-២០៣០នេះ បានលើកឡើងនូវគោលដៅជាយុទ្ធសាស្ត្រចំនួនប្រាំមួយ ដែលក្នុងនោះគោលដៅយុទ្ធសាស្ត្រចំនួនបួនមានជាលក្ខណៈថែទាំការពារផ្តោតសំខាន់លើការដោះស្រាយចំពោះបញ្ហាមាត់ធ្មេញរបស់កុមារតូច ការលើកកម្ពស់សុខភាពមាត់ធ្មេញកុមារតាមសាលារៀន ការថែទាំសុខភាពមាត់ធ្មេញសម្រាប់មនុស្សចាស់ និងបញ្ហាទាក់ទងនឹងជំងឺមហារីកប្រអប់មាត់ដែលស្ថិតក្រោមឥទ្ធិពលនៃមូលដ្ឋានគ្រឹះលើការពង្រឹងនិងកសាងសមត្ថភាពដឹកនាំនិងអភិបាលកិច្ច រួមទាំងការកសាងកម្លាំងធនធានមនុស្សផ្នែកទន្តសាស្ត្របានរឹងមាំ(រូបភាពទី១)។

## រូបភាពទី១៖ បង្ហាញពីទិដ្ឋភាពទូទៅនៃគោលដៅយុទ្ធសាស្ត្រទាំងប្រាំមួយ




### ៣.១- គោលការណ៍ណែនាំ

គោលដៅយុទ្ធសាស្ត្រដែលបានលើកឡើង ផ្អែកទៅលើគោលការណ៍ដូចខាងក្រោម៖

១. ការដឹកនាំផ្នែកទន្តសាស្ត្រប្រកបដោយប្រសិទ្ធភាព

២. អភិវឌ្ឍធនធានមនុស្សផ្នែកទន្តសាស្ត្រ

៣. អនុវត្តការគ្របដណ្តប់ជាសកល សម្រាប់ការថែទាំសុខភាពមាត់ធ្មេញ

គោលដៅនៃផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញ២០២៣-២០៣០ មានគោលបំណងក្នុងការបង្កើនលទ្ធភាពដើម្បីឱ្យប្រជាជនយ៉ាងតិចចំនួនមួយភាគបួន អាចទទួលបាននូវការថែទាំសុខភាពមាត់ធ្មេញតាមរយៈប្រព័ន្ធថែទាំសុខភាពបឋមនៅឆ្នាំ២០៣០។ គោលដៅសំខាន់មួយទៀត គឺអាចសម្រេចបាននូវការកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃជំងឺមាត់ធ្មេញចម្បងៗឱ្យបានប្រមាណ១០% ដើម្បីប្រជាជនមានសុខភាពមាត់ធ្មេញល្អប្រសើរឡើងពេញមួយជីវិត។

**គោលដៅយុទ្ធសាស្ត្រទី១៖** ពង្រឹងសមត្ថភាពដឹកនាំ អភិបាលកិច្ចនិងបណ្តាញទំនាក់ទំនងផ្នែកទន្តសាស្ត្រក្នុងការសម្របសម្រួលភាពជាដៃគូអន្តរវិស័យនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

១.១ ស្វែងរកការគាំទ្រមតិពីថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធ

១.២ ពង្រឹងនិងពង្រីកភាពជាអ្នកដឹកនាំផ្នែកទន្តសាស្ត្រនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

១.៣ ពង្រឹងកិច្ចសហការជាមួយដៃគូពាក់ព័ន្ធលើការងារសុខភាពមាត់ធ្មេញ

១.៤ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលដោយរួមបញ្ចូលផ្នែកសុខភាពមាត់ធ្មេញ

**គោលដៅយុទ្ធសាស្ត្រទី២៖**អភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សផ្នែកទន្តសាស្ត្រដើម្បីពង្រីកការគ្របដណ្តប់ជាសកលផ្នែកសុខភាពមាត់ធ្មេញ តាមរយៈការផ្តល់សេវាថែទាំបឋមដែលផ្តោតលើមនុស្សជាគោល

២.១ បណ្តុះបណ្តាលបន្តដល់មន្ត្រីផ្នែកទន្តសាស្ត្រថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់និងផ្តល់សេវាសុខភាពមាត់ធ្មេញប្រកបដោយគុណភាពខ្ពស់

២.២ ជំរុញនវានុវត្តន៍លើភាពជាគំរូនៃធនធានមនុស្សផ្នែកទន្តសាស្ត្រ

២.៣ បង្កើនការផ្គត់ផ្គង់ឱសថសារវន្ត ឧបករណ៍បរិក្ខារជាមូលដ្ឋាន និងបច្ចេកវិទ្យាសម្រាប់ការការពារ និងព្យាបាលជំងឺមាត់ធ្មេញ

**គោលដៅយុទ្ធសាស្ត្រទី៣៖** ពង្រឹងនិងជំរុញឱ្យមានការលើកកម្ពស់និងការថែទាំការពារសុខភាពមាត់ធ្មេញ លក្ខណៈជាសាកលសម្រាប់កុមារតូចនៅតាមសហគមន៍

៣.១ ដាក់បញ្ចូលការថែទាំសុខភាពមាត់ធ្មេញសម្រាប់ក្រុមកុមារតូចអាយុក្រោម៦ឆ្នាំ ទៅក្នុងប្រព័ន្ធថែទាំសុខភាពបឋម

៣.២ ពង្រីកសេវាគ្របដណ្តប់សុខភាពមាត់ធ្មេញជាសកលសម្រាប់ក្រុមកុមារតូចអាយុក្រោម៦ឆ្នាំ

**គោលដៅយុទ្ធសាស្ត្រទី៤៖** ជំរុញការលើកកម្ពស់សុខភាពមាត់ធ្មេញតាមគ្រឹះស្ថានសិក្សា

៤.១ ពង្រឹងនិងពង្រីកការលើកកម្ពស់និងការពារសុខភាពមាត់ធ្មេញសម្រាប់កុមារតាមគ្រឹះស្ថានសិក្សា ទៅក្នុងកម្មវិធីថែទាំសុខភាពដែលមានស្រាប់

៤.២ ពង្រីកសេវាគ្របដណ្តប់សុខភាពមាត់ធ្មេញជាសកលសម្រាប់កុមារតាមគ្រឹះស្ថានសិក្សា

**គោលដៅយុទ្ធសាស្ត្រទី៥៖** បង្កើតនិងជំរុញការផ្តល់សេវាថែទាំព្យាបាលមាត់ធ្មេញឱ្យបានសមស្រប សម្រាប់មនុស្សចាស់

៥.១ ដាក់បញ្ចូលការថែទាំសុខភាពមាត់ធ្មេញសម្រាប់មនុស្សចាស់ទៅក្នុងការថែទាំសុខភាពបឋម

៥.២ ពង្រឹងសមត្ថភាពធនធានមនុស្សផ្នែកទន្តសាស្ត្រ ដើម្បីបំពេញតម្រូវការលើការថែទាំសុខភាពមាត់ធ្មេញរបស់មនុស្សចាស់

**គោលដៅយុទ្ធសាស្ត្រទី៦៖** បង្កើនសមត្ថភាពស្រាវជ្រាវរកជំងឺមហារីកប្រអប់មាត់ ប្រភេទដំបៅកើតមាននៅមាត់និងថ្គាមដែលប្រឈមខ្ពស់ក្នុងការវិវត្តន៍ទៅជាជំងឺមហារីក និងពង្រឹងប្រព័ន្ធបញ្ជូន

៦.១ ធ្វើយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈអំពីជំងឺមហារីកប្រអប់មាត់និងប្រភេទដំបៅកើតមាននៅមាត់ដែលប្រឈមខ្ពស់ក្នុងការវិវត្តន៍ទៅជាជំងឺមហារីក

៦.២ ពង្រឹងការស្រាវជ្រាវរកជំងឺមហារីកប្រអប់មាត់ឱ្យទាន់ពេល តាមរយៈប្រព័ន្ធថែទាំសុខភាពបឋម។

## ៣.២- ចំណុចដៅជាក់លាក់នៅត្រឹមឆ្នាំ២០៣០

១. នៅត្រឹមឆ្នាំ២០៣០ មណ្ឌលសុខភាពប្រមាណ២៥% នៅក្នុងខេត្តដែលបានកំណត់ជ្រើសរើសនឹងទទួលបាននូវសេវាថែទាំសុខភាពមាត់ធ្មេញចាំបាច់។

២. នៅត្រឹមឆ្នាំ២០៣០ អត្រាប្រេវ៉ាឡង់នៃស្ថានភាពនិងជំងឺមាត់ធ្មេញចម្បងៗរបស់ប្រជាជននៅក្នុងខេត្តដែលបានកំណត់ជ្រើសរើស នឹងអាចកាត់បន្ថយបានប្រមាណ១០%។

# ៤- ផែនការសកម្មភាព

ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញឆ្នាំ២០២៣-២០៣០ ត្រូវបានរៀបចំក្នុងរយៈពេលវែង ស្របតាមផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការពារនិងប្រយុទ្ធនឹងជំងឺមិនឆ្លង២០២២-២០៣០ ។ សកម្មភាពលម្អិតដែលស្ថិតក្នុងតារាងសកម្មភាព លើកឡើងនូវរាល់សកម្មភាពទាំងអស់ដែលតម្រូវឱ្យមានការចូលរួមជាអន្តរវិស័យ ដើម្បីកាត់បន្ថយនូវបន្ទុកជំងឺមាត់ធ្មេញក្នុងចំណោមប្រជាជនកម្ពុជា។

## ៤.១- ទិសាលភាពនៃផែនការ

ផែនការសកម្មភាពជាតិសុខភាពមាត់ធ្មេញ២០២៣-២០៣០ បានកំណត់នូវសកម្មភាពចម្បងៗនិងសូចនាករដែល ចែកចេញតាមគោលដៅយុទ្ធសាស្ត្រចំនួន៦ រួមមានទាំងក្របខណ្ឌពេលវេលា និងអង្គភាពទទួលខុសត្រូវ ដែលមានក្នុងតារាងសកម្មភាពដូចខាងក្រោម។

## ៤.២- តារាងសកម្មភាពការងារ

| សកម្មភាពសំខាន់ៗ | | ក្របខណ្ឌពេលវេលា | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|
| **គោលដៅយុទ្ធសាស្ត្រទី១៖** ពង្រឹងសមត្ថភាពដឹកនាំ អភិបាលកិច្ច និងបណ្តាញទំនាក់ទំនងផ្នែកទន្តសាស្ត្រក្នុងការសម្របសម្រួលភាពជាដៃគូអន្តរវិស័យនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | | | |
| **១.១** | ស្វែងរកការគាំទ្រមតិពីថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធ | | |
| ១.១.១ | រៀបចំឯកសារជាសក្ខីកម្មស្តីពីការលើកកម្ពស់សុខភាពមាត់ធ្មេញ ដើម្បីស្វែងរកការគាំទ្រមតិពីថ្នាក់ដឹកនាំក្នុងការបង្ការជំងឺមាត់ធ្មេញនៅក្នុងប្រទេសកម្ពុជា (ឧទា.ការកាត់បន្ថយជាតិស្ករ ការប្រើប្រាស់សារជាតុភ្លុយអរ៉ាយ ការបន្ធូរបន្ថយពន្ធដារសម្រាប់ផលិតផលដែលមានសារជាតុភ្លុយអរ៉ាយ និងការកាត់បន្ថយកត្តាហានិភ័យនានា) | ២០២៤-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-អនុគណៈកម្មការបច្ចេកទេសផ្នែកសុខភាពមាត់ធ្មេញ<br>-ស្ថាប័ននិងដៃគូពាក់ព័ន្ធ |
| ១.១.២ | គៀងគរប្រភពថវិកាពីដៃគូ សប្បុរសជនសម្រាប់ការអភិវឌ្ឍលើការផ្តល់សេវាសុខភាពមាត់ធ្មេញសាធារណៈ | ២០២៤-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព |
| ១.១.៣ | អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្នែកសុខភាពមាត់ធ្មេញសាធារណៈ នៅតាមមន្ទីរពេទ្យខេត្ត/បង្អែក | ២០២៤-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរសុខាភិបាលរាជធានី/ខេត្ត |

| | | | |
|---|---|---|---|
| **១.២** | **ពង្រឹងនិងពង្រីកភាពជាអ្នកដឹកនាំផ្នែកទន្តសាស្ត្រនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ** | | |
| ១.២.១ | បង្កើនសមត្ថភាពដល់អ្នកមានវិជ្ជាជីវៈផ្នែកទន្តសាស្ត្ររួមទាំងមន្ត្រីទទួលបន្ទុកការិយាល័យសុខភាពមាត់ធ្មេញ តាមរយៈការចូលរួមវគ្គសិក្សានិងវគ្គបណ្តុះបណ្តាលនានា ដើម្បីពង្រឹងការងារដឹកនាំ និងបណ្តាញទំនាក់ទំនង (ឧទា. ផ្នែកសុខភាពសាធារណៈ ផ្នែករដ្ឋបាលសាធារណៈ ការងារដឹកនាំគ្រប់គ្រង និងផ្នែកសិក្សាអង្កេតស្រាវជ្រាវ ជាដើម។ល។) | ២០២៣-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-គណៈទន្តពេទ្យកម្ពុជា<br>-មន្ទីរសុខាភិបាលរាជធានី/ខេត្ត<br>-គ្រឹះស្ថានបណ្តុះបណ្តាល |
| **១.៣** | **ពង្រឹងកិច្ចសហការជាមួយដៃគូពាក់ព័ន្ធលើការងារសុខភាពមាត់ធ្មេញ** | | |
| ១.៣.១ | ធ្វើបច្ចុប្បន្នភាពអនុគណៈកម្មការបច្ចេកទេសសុខភាពមាត់ធ្មេញ រួមទាំងសមាជិកភាព តួនាទី និងភារកិច្ច | ២០២៣-២០៣០ | -ការិ.សុខមាត់ធ្មេញ/នា.ការពារសុខភាព<br>-អនុគណៈកម្មការបច្ចេកទេសផ្នែកសុខភាពមាត់ធ្មេញ<br>-ស្ថាប័ននិងដៃគូពាក់ព័ន្ធ |
| ១.៣.២ | អភិវឌ្ឍន៍ប្រធានបទស្តីពីសុខភាពមាត់ធ្មេញសម្រាប់ចែកចាយបែបវេទិកាឌីជីថល ជាផ្នែកមួយនៃគេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល និងទំព័រផ្លូវការរបស់មន្ទីរសុខាភិបាលរាជធានី/ខេត្ត (ដូចជាសារអប់រំ សេវាផ្តល់ការថែទាំព្យាបាល និងសេវាបញ្ជូនក្នុងករណីចាំបាច់ជាដើម។ល។) | ២០២៥-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-នា.ផែនការនិងព័ត៌មានសុខាភិបាល<br>-មន្ទីរសុខាភិបាលរាជធានី/ខេត្ត<br>-ស្ថាប័ននិងដៃគូពាក់ព័ន្ធ |
| ១.៣.៣ | រៀបចំរចនាសម្ព័ន្ធ "ផ្នែកសុខភាពមាត់ធ្មេញ" នៅតាមមន្ទីរសុខាភិបាលរាជធានី/ខេត្ត | ២០២៤-២០២៥ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-មន្ទីរសុខាភិបាលរាជធានី/ខេត្ត |
| ១.៣.៤ | រៀបចំក្រុមការងារសម្របសម្រួលថ្នាក់រាជធានី/ខេត្ត ដើម្បីអនុវត្តសកម្មភាពសុខភាពមាត់ធ្មេញ តាមគ្រឹះស្ថានសិក្សា និងនៅក្នុងសហគមន៍ | ២០២៣-២០៣០ | -ការិ.សុខមាត់ធ្មេញ/នា.ការពារសុខភាព<br>-មន្ទីរអប់រំយុវជននិងកីឡាខេត្ត<br>-មន្ទីរសុខាភិបាលរាជធានី/ខេត្ត<br>-ស្ថាប័ននិងដៃគូពាក់ព័ន្ធ |
| ១.៣.៥ | បង្កើតក្រុមការងារសម្រាប់រៀបចំកំណត់របៀបវារៈនៃការសិក្សាស្រាវជ្រាវស្តីពីសុខភាពមាត់ធ្មេញ ដោយផ្តល់អាទិភាពដល់ការសិក្សាស្រាវជ្រាវដែលជាជំនួយក្នុងការអនុវត្តផែនការសកម្មភាពបច្ចុប្បន្ន | ២០២៤-២០២៥ | -វិទ្យាស្ថានជាតិសុខភាពសាធារណៈ<br>-ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-គ្រឹះស្ថានបណ្តុះបណ្តាល |
| ១.៣.៦ | បង្កើតទម្រង់របាយការណ៍ស្តីពីការលើកកម្ពស់សុខភាពមាត់ធ្មេញសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ស្របតាមទម្រង់របាយការណ៍របស់ក្រសួងសុខាភិបាលដែលមានស្រាប់ | ២០២៣-២០២៦ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-ស្ថាប័ននិងដៃគូពាក់ព័ន្ធ |
| **១.៤** | **ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលដោយរួមបញ្ចូលផ្នែកសុខភាពមាត់ធ្មេញ** | | |
| ១.៤.១ | បញ្ចូលព័ត៌មានផ្នែកសុខភាពមាត់ធ្មេញទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល | ២០២៣-២០៣០ | -ការិ.សុខមាត់ធ្មេញ/នា.ការពារសុខភាព<br>-នា.ផែនការនិងព័ត៌មានសុខាភិបាល |

| | | | |
|---|---|---|---|
| ១.៤.២ | វាយតម្លៃការផ្តល់សេវាកម្មផ្នែកសុខភាពមាត់ធ្មេញដោយផ្អែកលើសូចនាករដែលបានកំណត់ក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល | ២០២៤-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-នា.ផែនការនិងព័ត៌មានសុខាភិបាល |
| ១.៤.៣ | ធ្វើការសិក្សាអង្កេតស្រាវជ្រាវថ្នាក់ជាតិផ្នែកសុខភាពមាត់ធ្មេញដោយយោងទៅតាមចំណុច១.៣.៥ខាងលើ(មួយដង) | ២០២៦-២០៣០ | -វិទ្យាស្ថានជាតិសុខភាពសាធារណៈ<br>-ការិ.សុខមាត់ធ្មេញ/នា.ការពារសុខភាព<br>-ស្ថាប័ននិងដៃគូពាក់ព័ន្ធ |
| ១.៤.៤ | បង្កើតគេហទំព័ររបស់ការិយាល័យសុខភាពមាត់ធ្មេញនៃនាយកដ្ឋានការពារសុខភាព | ២០២៤-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព |
| **គោលដៅយុទ្ធសាស្ត្រទី២៖** អភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សផ្នែកទន្តសាស្ត្រ ដើម្បីពង្រីកការគ្របដណ្តប់ជាសកលផ្នែកសុខភាពមាត់ធ្មេញ តាមរយៈការផ្តល់សេវាថែទាំបឋមដែលផ្តោតលើមនុស្សជាគោល | | | |
| **២.១** | បណ្តុះបណ្តាលបន្តដល់មន្ត្រីទន្តសាស្ត្រថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់និងផ្តល់សេវាសុខភាពមាត់ធ្មេញប្រកបដោយគុណភាពខ្ពស់ | | |
| ២.១.១ | រៀបចំវគ្គបណ្តុះបណ្តាលបន្តដល់មន្ត្រីផ្នែកទន្តសាស្ត្រ ដើម្បីទទួលបានចំណេះដឹងបំពេញបន្ថែមលើ (ឧទាហរណ៍.ការថែទាំជាពិសេសក្នុងវិស័យទន្តសាស្ត្រ ការងារបច្ចេកទេសនៃការផ្តល់សេវា និងផ្នែកសិក្សាអង្កេតស្រាវជ្រាវ) | ២០២៤-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-មន្ទីរពេទ្យជាតិ<br>-មន្ទីរសុខាភិបាលរាជធានី/ខេត្ត<br>-គ្រឹះស្ថានបណ្តុះបណ្តាល |
| ២.១.២ | រៀបចំវគ្គបណ្តុះបណ្តាលបន្តដល់មន្ត្រីទន្តសាស្ត្រនៅតាមមូលដ្ឋានលើផ្នែកបច្ចេកទេសនានា ដោយផ្តោតលើការផ្តល់សេវាថែទាំសុខភាពមាត់ធ្មេញចាំបាច់ (ដូចជា៖ Minimally invasive dentistry ការលាបក្លួយអ៊ោយការពារឬទប់ស្កាត់ជំងឺពុកធ្មេញជាដើម)យ៉ាងតិច២ដងក្នុង១ឆ្នាំ | ២០២៤-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-គ្រឹះស្ថានបណ្តុះបណ្តាល<br>-មន្ទីរសុខាភិបាលរាជធានី/ខេត្ត<br>-ស្ថាប័ននិងដៃគូពាក់ព័ន្ធ |
| ២.១.៣ | រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការការពារចម្លងមេរោគក្នុងគ្លីនិកទន្តសាស្ត្រ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈយ៉ាងតិច២ដងក្នុង១ឆ្នាំ | ២០២៤-២០៣០ | -ការិយាល័យសុខភាពមាត់ធ្មេញ/នាយកដ្ឋានការពារសុខភាព<br>-មន្ទីរសុខាភិបាលរាជធានី/ខេត្ត<br>-ស្ថាប័ននិងដៃគូពាក់ព័ន្ធ |
| **២.២** | ជំរុញនវានុវត្តន៍លើភាពជាគំរូនៃធនធានមនុស្សផ្នែកទន្តសាស្ត្រ | | |
